*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ២៦ អនក្រ
# ស្តីពីការប្តូរឈ្មោះទីរួមខេត្ត
# សង្កាត់ ក្នុងខេត្តកំពង់ធំ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះទីរួមខេត្តរបស់ខេត្ត កំពង់ធំ មកជាស្រុក ស្ទឹងសែន ដែលមានទីតាំងរដ្ឋបាលសាលាស្រុកនៅភូមិ កំពង់ធំ ឃុំ កំពង់រទេះ ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះ សង្កាត់ចំនួនប្រាំបួន ចំណុះទីរួមខេត្តមកជាឃុំចំនួនប្រាំបួន ចំណុះស្រុកស្ទឹងសែន ។

សង្កាត់ ១ មកជា ឃុំ ដំរីជាន់ខ្លា

សង្កាត់ ២ មកជា ឃុំ កំពង់ធំ

សង្កាត់ ៣ មកជា ឃុំ កំពង់រទេះ

សង្កាត់ ៤ មកជា ឃុំ អូរកន្ធរ

សង្កាត់ ៥ មកជា ឃុំ ក្តីដូង

សង្កាត់ ៦ មកជា ឃុំ កំពង់ក្របៅ

សង្កាត់ ៧ មកជា ឃុំ ព្រៃគុយ

សង្កាត់ ៨ មកជា ឃុំ ព្រៃតាហ៊ូ

សង្កាត់ ៩ មកជា ឃុំ អាចារ្យលាក់

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

www.pheakdeylaw.com

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត កំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៥ :** អនុក្រឹត្យនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ២៧ អនក្រ
## ស្តីពីការប្តូរឈ្មោះស្រុក ទីរួមខេត្ត
## សង្កាត់ក្នុងខេត្តស្វាយរៀង

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះស្រុកស្វាយរៀង មកជាស្រុកស្វាយជ្រំ ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះទីរួមខេត្តរបស់ខេត្តស្វាយរៀង មកជាស្រុកស្វាយរៀងដែលមានទីតាំងរដ្ឋបាលសាលាស្រុកនៅភូមិទី ៣ ឃុំស្វាយរៀង ។

**មាត្រា ៣ :** ត្រូវបានប្តូរឈ្មោះសង្កាត់ចំនួន ០៤ ចំណុះទីរួមខេត្ត មកជាឃុំចំនួន ០៤ ចំណុះស្រុកស្វាយរៀងគឺ :

www.pheakdeylaw.com